# ដើមបណ្តឹងរដ្ឋប្បវេណីគោរពដួងព្រលឹងអ្នកដែលបាត់បង់ជីវិត

***ដោយ ម៉ៃខឹល សាលីបា និង ថៃល័រ នីមស៍***

***ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០***

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

មុនថ្ងៃប្រកាសសេចក្តីសម្រេចកាត់ទោសជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រធានគុកទួលស្លែង (មន្ទីរស-២១) ដើមបណ្តឹងរដ្ឋប្បវេណីរបស់រឿងក្តី ឌុច បានចូលរួមពិធីប្រពៃណីរបស់ពុទ្ធសាសនិក នៅក្នុងបរិវេណគុកនេះដែលបច្ចុប្បន្នបានក្លាយជាសារមន្ទីរ ដើម្បីគោរពដួងព្រលឹងបុរសនិងស្ត្រី ដែលត្រូវបានសម្លាប់នៅទីនោះ និងនៅវាលពិឃាតជើងឯក ។ ដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមគ្រួសាររបស់ខ្លួនបានអុជធូប និងថ្វាយផ្កាឈូក និងគ្រឿងសក្ការៈដល់ព្រះសង្ឃសម្រាប់បងប្អូន ក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតទៅ ។ បន្ទាប់មកទៀត ព្រះសង្ឃបានសូត្រធម៌ប្រោះព្រំវេរ គ្រឿងជផ្កាយដល់អ្នកដែលស្លាប់បាត់បង់ជីវិតទាំងអស់នោះ ។

នេះគឺជាការប្រារព្ធពិធីដ៏ស្រងូតស្រងាត់បំផុតមួយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមគ្រួសាររបស់ខ្លួន ដោយសារតែអ្នកទាំងអស់នេះបានវិលត្រឡប់មកទីកន្លែងដែលបងប្អូនសាច់ញាតិរបស់គេត្រូវបានធ្វើទារុណកម្ម និងបញ្ចប់ជីវិត ។ តាមទំនៀមទម្លាប់ប្រពៃណី ការប្រារព្ធពិធីនេះតែងតែធ្វើឡើងនៅតាមផ្ទះ ឬកន្លែងកប់ ឬដាក់អដ្ឋិធាតុបងប្អូនសាច់ញាតិដែលបានស្លាប់បាត់បង់ជីវិតទៅ ។ ប៉ុន្តែ គួរឲ្យស្តាយ ដោយសារតែមានប្រជាជនកម្ពុជាជាច្រើនបានស្លាប់នៅក្នុងកំឡុងរបបខ្មែរក្រហម សាកសពជាច្រើនរបស់អ្នកដែលបាត់ខ្លួនពីមន្ទីរស-២១ និងនៅជើងឯក ទាំងអស់មិនអាចរកឃើញ និងស្គាល់អត្តសញ្ញាណឡើយ ។ ក្រោយពេលដែលពិធីនេះបានបញ្ចប់ផុតទៅ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនរួមទាំងក្រុមគ្រួសាររបស់ខ្លួន បាននិយាយជាមួយនឹងអ្នកយាំមើលដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ដោយបានបញ្ចេញនូវកំហឹង និងការឈឺចាប់ ។ ប៉ុន្តែជាមួយគ្នានេះ អ្នកទាំងនោះ ក៏បានបង្ហាញពីក្តីសង្ឃឹមរបស់ខ្លួនដែលថាការសម្រេចកាត់ទោសនៅថ្ងៃស្អែកនេះនឹងយ៉ាងហោចណាស់ផ្តល់នូវយុត្តិធម៌ ។

ជាមួយគ្នានេះ មានព្រឹត្តិការណ៍ដ៏ចម្លែកមួយទៀតបានកើតឡើង នោះគឺដំបូលអគារដែលជាអតីតគុកឃុំឃាំងអ្នកទោសបានបាក់ធ្លាក់ចុះដោយសារភ្លៀងធ្លាក់កាលពីប៉ុន្មានថ្ងៃមុន ។ មានប្រជាជនមួយចំនួន

បានយល់ឃើញថាការបាក់ធ្លាក់ចុះនៃដំបូលអគារនេះគឺជាកំហឹង ឬការអន្ទះអន្ទែងរបស់វិញ្ញាណក្ខន្ធដែល រំពឹងរង់ចាំសេចក្តីសម្រេចកាត់ទោសនៅថ្ងៃស្អែកនេះ ។